៤- ក្រសួង ស្ថាប័ន ខេត្ត ក្រុង នីមួយ ៗ ត្រូវរៀបចំចាត់ចែងអោយមាន កម្មវិធីអនុវត្តការងារ សន្សំសំចៃរៀងៗ ខ្លួន សំដៅប្រមែប្រមូលទុនដែលបានមកពីការសន្សំសំចៃនេះ យកទៅអភិវឌ្ឍន៍ភូមិឃុំណាដែលក្រក្សត់ជាងគេ ។

៥- ក្រសួងអប់រំយុវជន និង កីឡា ត្រូវរៀបចំបញ្ចូលទៅក្នុងកម្មវិធីសិក្សាផ្នែកបឋម សិក្សាអំពីការងារសន្សំសំចៃ ។

ក្រោយពេលទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នរដ្ឋ និង គ្រប់ខេត្ត ក្រុង ចាត់ចែងផ្សព្វផ្សាយអោយបាន ទូលំទូលាយដល់មន្ត្រីរាជការទាំងអស់ក្រោមឱវាទ សំដៅអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀងៗខ្លួន ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា — ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤*

## សារាចរលេខ ០៨ សរ

## ស្តីពីការជំរុញការងារបង្កបង្កើនផលរដូវប្រាំង

## ១៩៩៤ -១៩៩៥ និងរដូវវស្សា ១៩៩៥

ការងារបង្កបង្កើនផលរដូវវស្សា ១៩៩៤ កន្លងទៅនេះ បានជួបប្រទះនូវផលវិបាកជាច្រើនដែលបណ្តាលមកពីគ្រោះទឹកជំនន់ដែលបានបំផ្លាញអស់ផលដំណាំជាច្រើន ពិសេសដំណាំស្រូវដែលត្រូវទទួលការខូចខាតរាប់រយពាន់ ហ.ត ។ ទន្ទឹមនឹងគ្រោះទឹកជំនន់ដ៏សាហាវនេះ គ្រោះរាំងស្ងួតចុងរដូវវស្សាក៏បានរាតត្បាតលើតំបន់មួយចំនួនគួរអោយព្រួយបារម្ភ ។ បើរាជរដ្ឋាភិបាលពុំមានវិធានការក្នុងការអន្តរាគមន៍សង្គ្រោះទាន់ពេលវេលាទេនោះ ផ្ទៃដីដាំស្រូវមួយចំនួនធំត្រូវទទួលការខូចខាតយ៉ាងធំធេងដែលអាចនឹងជួបការលំបាកដោយសារការខ្វះខាតស្បៀង យ៉ាងធ្ងន់ធ្ងរសំរាប់ ឆ្នាំ ១៩៩៥ ដែលរាជរដ្ឋាភិបាលត្រូវប្រឈមមុខដោះស្រាយ ។ ចំពោះមុខសភាពការណ៍ដ៏សាហាវធ្ងន់ៗនេះ រាជរដ្ឋាភិបាលតាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ និង រដ្ឋអំណាចគ្រប់

ជាន់ថ្នាក់បានយកចិត្តទុកដាក់ខិតខំប្រឹងប្រែងប្រើគ្រប់មធ្យោបាយ ដែលមានដើម្បីដោះស្រាយ និងស្តារសភាពការណ៍បានមួយចំនួន ។

ដើម្បីកាត់បន្ថយកង្វះខាតស្បៀងដែលបណ្តាលមកពីគ្រោះធម្មជាតិទឹកជំនន់ និងរាំងស្ងួតខាងលើ ព្រមទាំងត្រៀមលក្ខណៈអោយបានល្អ សំរាប់ការងារបង្កបង្កើនផលរដូវប្រាំង ១៩៩៤-៩៥ និងរដូវវស្សា ១៩៩៥ រាជរដ្ឋាភិបាលសូមលើកឡើង នូវការណែនាំ និងកំណត់បញ្ហាដោះស្រាយមួយចំនួនដូចតទៅ :

១- ការសង្គ្រោះសន្ទូងរដូវវស្សា ១៩៩៤ :

- ចំពោះមុខក្នុងលក្ខណៈសង្គ្រោះបន្ទាន់នេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់ បន្តផ្គត់ផ្គង់មាស៊ីនបូមទឹក និងប្រេងឥន្ធនៈសំរាប់បូមទឹកដល់តំបន់ដែលទទួលរងគ្រោះរាំងស្ងួត ហើយដែលមានលទ្ធភាពប្រភពទឹក ដើម្បីធានាដល់ការសង្គ្រោះផ្ទៃដីសន្ទូងអោយបានច្រើនជាអតិបរមា ។ ទន្ទឹម នឹងនេះ ត្រូវចាត់តាំងមន្ត្រីរាជការចុះតាមការដ្ឋានបូមទឹកនីមួយៗ ដើម្បីសំរបសំរួលការងារដោះស្រាយរាល់បញ្ហា សំខាន់ៗ ទាំង ឡាយដែលពាក់ព័ន្ធដល់ការងារបូមទឹក និងមានវិធានការផ្សេងៗក្នុងករណីចាំបាច់ ។

- រដ្ឋអំណាចមូលដ្ឋាន ចាប់ពីថ្នាក់ខេត្ត ស្រុក រហូតដល់ឃុំភូមិ ត្រូវក្តាប់អោយបានចំណុចរងគ្រោះដោយការរាំងស្ងួតទាំងឡាយដើម្បីមានវិធានការដោះស្រាយបានទាន់ពេលវេលា ។ ក្នុងតំបន់ដែលមានប្រភពទឹកអាចបូមបាន ឬ បង្ហូរ បានត្រូវមានវិធានការចាត់ចែងប្រើប្រាស់ទឹក និងមធ្យោបាយដែលមានអោយបានសមស្រប និងអោយអស់លទ្ធភាព ចៀសវាងកុំអោយមានទំនាស់រវាងកសិករ ឬ រវាងកសិករ និងរដ្ឋអំណាច ។ ត្រូវក្តាប់អោយបានការងារបង្កបង្កើនផល រដូវវស្សា ១៩៩៤ ទាំងផ្ទៃដី ទាំងបរិមាណផល ព្រមទាំងវាយតម្លៃលើលទ្ធភាពស្បៀងសំរាប់ឆ្នាំ ១៩៩៥ ។

- ក្រសួងកសិកម្ម រដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវបូកសរុបលទ្ធផលនៃការងារអន្តរាគមន៍សង្គ្រោះនេះជូន គណៈរដ្ឋមន្ត្រីជ្រាបនៅពេលចប់កិច្ចប្រតិបត្តិការ ។

២- ការបង្កបង្កើនផលស្រូវរដូវប្រាំង ឆ្នាំ ១៩៩៤-៩៥ :

ចំពោះរដូវប្រាំង ១៩៩៤-៩៥ ខាងមុខក្រសួងជំនាញ និងរដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវចាត់តាំងមន្ត្រីរាជការ និងមន្ត្រីជំនាញកសិកម្មអោយចុះតាមការដ្ឋានស្រូវប្រាំង និងស្រូវប្រដេញទឹកទាំងអស់

ដើម្បីចលនាប្រជាកសិករប្រួសរាន់ប្រមូលផលស្រូវវស្សា ជំរុញការស្រូវប្រាំង និងពង្រីកផ្ទៃដីស្រូវប្រាំង ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងមានវិធានការដោះស្រាយរាល់បញ្ហាដែលកើតមានឡើង ដូចជាកង្វះខាតទឹកកង្វះខាតពូជ សំភារៈមធ្យោបាយផលិតកម្មផ្សេង ៗ ។

- ក្រសួងកសិកម្មត្រូវត្រៀមលក្ខណៈ ម៉ាស៊ីនបូមទឹក ប្រេងឥន្ទនៈ ស្រូវពូជ និង ឧបករណ៍សំភារៈមធ្យោបាយផ្សេង ៗ ដើម្បីផ្គត់ផ្គង់ដល់តំបន់ធ្វើស្រូវប្រាំងអោយបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

- ក្រសួងកសិកម្មត្រូវផ្គត់ផ្គង់ ស្រូវពូជ ពូជដំណាំស្បៀងរួមផ្សំ ចំពោះតំបន់ ឬ គ្រួសារដែលបានទទួលការរង គ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ហើយដែលមានលទ្ធភាពធ្វើស្រែប្រាំងបាន ព្រមទាំងគ្រួសារណាដែលមានលទ្ធភាពពង្រីកផ្ទៃដីស្រូវប្រាំង ។ ត្រូវចាត់តាំងធ្វើថ្នាលសំណាបរួម ដើម្បីត្រៀមលក្ខណៈផ្ដល់សំណាបដល់ប្រជាកសិករដែលត្រូវ ការសំណាប ហើយពុំមានលទ្ធភាពសាបសំណាបបានទាន់ពេលវេលា ។

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់ត្រូវវិធានការសមស្របដើម្បីផ្គត់ផ្គង់ ជីគីមី ថ្នាំសម្លាប់សត្វល្អិត ឧបករណ៍កសិកម្មអោយដល់ដៃប្រជាកសិករតាមរយៈការទូទាត់ ។ តែចំពោះគ្រួសារដែលទទួលការរងគ្រោះ ពុំមានលទ្ធភាពទូទាត់ដល់ដៃនូវសំភារៈ មធ្យោបាយផលិតកម្មទាំងនោះបានគប្បីអនុញ្ញាតអោយទិញជឿ ហើយទូទាត់វិញនៅពេលប្រមូលផលរួច ។ រដ្ឋអំណាចមូលដ្ឋាន ត្រូវធានាអោយការទូទាត់នេះប្រព្រឹត្តិទៅបានល្អ ។

- ត្រូវបំផុសចលនាប្រជាកសិករដាំដំណាំស្បៀងរួមផ្សំដូចជា ដំឡូងមី ពោត សណ្ដែក ។ ល ។ អោយបានច្រើន ដើម្បីជំនួសស្រូវអង្ករដែលខ្វះខាតនៅតាមតំបន់រងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ហើយដែលមានលទ្ធភាពអាច ដាំដុះបាន ។

- ចំពោះ ម៉ាស៊ីនបូមទឹក ដែលតាំងរួចហើយសំរាប់អន្តរាគមន៍សង្គ្រោះសន្ទូងនាចុងរដូវវស្សា ១៩៩៤នេះ គប្បីរក្សាទុកដដែល ដើម្បីបំរើដល់ការបូមស្រោចស្រពសំរាប់រដូវប្រាំងខាងមុខ ឬចល័តទៅកន្លែងដែលមានស្រូវប្រាំងច្រើន ។ ត្រូវចលនាប្រជាកសិករអោយប្រើប្រាស់ឧបករណ៍បាចទឹកបុរាណដូចជា រហ៊ាត ស្នាច យោង ។ ល ។

កងយោធពលខេមរភូមិន្ទ កងកំលាំងសន្តិសុខជាតិ កងជីវពល អាជ្ញាធរមូលដ្ឋាន ត្រូវរួមសហការពង្រឹងការពារ ដើម្បីប្រជាកសិករ មានលទ្ធភាពពង្រីកផ្ទៃដាំដុះ និងច្រូតកាត់ប្រមូលផល បានដោយសុវត្ថិភាព ។

គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ ខេត្ត-ក្រុង និងអង្គភាពពាក់ពន្ធ័ ត្រូវសហការគ្នាអោយជិតស្និទ្ធអនុវត្តខ្លឹមសារសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់ អោយសមស្របទៅតាមមូលដ្ឋាននីមួយ ៗ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

***

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤*

## សារាចរលេខ ០៩ សរច
## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃយន្តការ « ចំណុចប្រមូលផ្តុំ » និង » ច្រកចេញ ចូល តែមួយ » របស់គណៈ កម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ( គ.ជ.នា )

យោងតាមមាត្រាទី ៣ មាត្រាទី៤ និងមាត្រាទី៥ ជំពូកទី២ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងនៅក្នុងពេលរង់ចាំការកំណត់ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមអនុក្រឹត្យ និងដើម្បីដំណើរការកិច្ចការនិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំកិច្ចដំណើរការរបស់យន្តការ " ចំណុចប្រមូលផ្តុំ " និង "ច្រកចេញ ចូលតែមួយ " របស់ គណៈកម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ( គ.ជ.នា ) ដូចខាងក្រោម :

១- យន្តការ " ចំណុចប្រមូលផ្តុំ " :

គណៈកម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ( គ.ជ.នា ) គឺជា " ចំណុចប្រមូលផ្តុំ " ក្នុងរាល់ទំនាក់ទំនងរវាងបណ្តាស្ថាប័នរបស់រាជរដ្ឋាភិបាល និងបណ្តាអង្គការ និងស្ថាប័នផ្តល់ជំនួយទាំងអស់មកដល់ព្រះរាជាណាចក្រកម្ពុជា ។ គ.ជ.នា មានភារកិច្ចផ្តល់ទៅអោយក្រុមបេសកកម្មនៃអង្គការ និងស្ថាប័នផ្តល់ជំនួយទាំងនោះ